# កិច្ចសម្ភាសរបស់ ញៀម សុគន្ធា ពីចំណាប់អារម្មណ៍ និង បទពិសោធន៍ដែលគាត់មានទាក់ទងនឹងគម្រោងផ្ទាល់មាត់របស់ជនជាតិខ្មែរ

ខ្ញុំឈ្មោះញៀម សុគន្ធា។ ខ្ញុំជាអ្នកដឹកនាំ Peer Leader សម្រាប់គម្រោង ប្រវត្តិផ្ទាល់មាត់របស់ប្រជាជនកម្ពុជាអស់រយៈពេលបីឆ្នាំ។ ខ្ញុំបានចូលរួមជាមួយគម្រោងនេះភ្លាម បន្ទាប់ពីខ្ញុំត្រឡប់មកពីការបម្រើជាអ្នកផ្សព្វផ្សាយសាសនាវិញ សម្រាប់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ ដំបូងខ្ញុំបានដឹងអំពីគម្រោងនេះពីអ្នកផ្សព្វផ្សាយសាសនាម្នាក់ឈ្មោះ Tyler Jorgensen នៅពេលដែលគាត់កំពុងធ្វើការឱ្យគម្រោងនេះនៅប្រទេសកម្ពុជា។

ក្នុងនាមជាអ្នកដឹកនាំ Peer Leader ម្នាក់ ខ្ញុំទៅសម្ភាសប្រជាជនខ្មែរដូចជាបងប្អូនខ្ញុំ និង ពេលខ្លះអ្នកដែលខ្ញុំមិនដែលស្គាល់ពីមុនមក។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើនខ្ញុំធ្វើការសម្ភាសអ្នកដែលខ្ញុំស្គាល់ច្បាស់ ដូចជាឪពុកម្តាយ បងប្រុសខ្ញុំ និងអ្នកដែលមានបទពិសោធន៍នៅក្នុងជីវិតច្រើនដូចជា ជីដូនជីតា និងសមាជិកក្រុមគ្រួសារពួកគាត់។ ខ្ញុំព្យាយាមរក្សាប្រវត្តិក្រុមគ្រួសាររបស់ខ្ញុំផ្ទាល់សិន។ ក្រៅពីការសម្ភាស ខ្ញុំក៏វាយការសម្ភាសទាំងអស់នោះទៅជាអត្ថបទ។

ក្រៅពីការងាររបស់ខ្ញុំជាអ្នកដឹកនាំ Peer Leader ខ្ញុំកំពុងរៀនលេងកូតវីយូឡុង។ ខ្ញុំលេងមិនសូវល្អទេហើយគិតថាការលេងវីយូឡុងពិបាក ប៉ុន្តែខ្ញុំនៅតែចូលចិត្តលេងវា។ ក្រៅពីរៀនលេងកូតវីយូឡុង ខ្ញុំក៏ចូលចិត្តទៅលេងចម្ការផងដែរ ហើយមានក្តីស្រម៉ៃថាថ្ងៃណាមួយចង់មានចម្ការខ្លួន ហើយដាំដើមផ្លែឈើហូបផ្លែ និង រុក្ខជាតិជាច្រើន ជាពិសេស ខ្ញុំចង់ដាំផ្លែឡាមើដោយសារវាឆ្ងាញ់ ហើយមនុស្សនៅជុំវិញពិភពលោក គេចូលចិត្តញ៉ាំផ្លែមួយហ្នឹង។ កន្លែងដែលខ្ញុំចូលចិត្តទៅលេងគឺខេត្តមណ្ឌលគិរី ដោយសារវាជាខេត្តមួយដែលស្អាត ហើយម្នាក់ៗចូលចិត្តទៅលេងខេត្តហ្នឹង ដោយសារវាមានព្រៃ មានភ្នំច្រើនមែនទែន។ កន្លែងដែលខ្ញុំចង់ដាំដំណាំ គឺមិនមែននៅទៅហ្នឹង តែនៅកន្លែងដែលមានទេសភាពស្រដៀងនៅទីហ្នឹងដែរ។ សម្រាប់ការងារសម្ភាស ខ្ញុំធ្លាប់តែសម្ភាសអ្នកធ្វើស្រែ ប៉ុន្តែមិនដែលធ្លាប់បានសម្ភាសអ្នកចម្ការទេ ប៉ុនខ្ញុំបានគិតជាយូរមកហើយថាមានបំណងចង់សម្ភាសអ្នកធ្វើចម្ការដាំគ្រាប់ស្វាយចន្ទី

ដែលខ្ញុំបានស្គាល់។ ពួកគាត់មានបទពិសោធន៍ច្រើននៅក្នុងជីវិត។ អញ្ចឹងខ្ញុំមានបំណងថានឹងសម្ភាសពួកគាត់។

ខ្ញុំធ្លាប់មានបទពិសោធសម្ភាសមនុស្សជាច្រើន ជាពិសេសចាស់ៗដែលគាត់ធ្លាប់ឆ្លងកាត់ការលំបាកច្រើនជាយើង ហើយពួកគាត់បានឃើញពន្លឺថ្ងៃមុនយើង។ សម្រាប់ប្រជាជនខ្មែរ អ្នកដែលចាស់ៗ គាត់បានឆ្លងកាត់នូវសង្គ្រាម សម្ភាស ១០០ នាក់ គាត់បានឆ្លងកាត់សង្គ្រាមទាំង ១០០នាក់ហើយ។ អញ្ចឹងជីវិតរបស់គាត់  គាត់បានឆ្លងកាត់នូវរឿងរ៉ាវច្រើនមែនទែន គាត់បានប្រាប់ខ្ញុំនូវដំណើររឿងនៃជីវិត ពីការតស៊ូព្យាយាមនៅក្នុងជីវិតរបស់ពួកគាត់ ទម្រាំគាត់បានរស់មកដល់សព្វថ្ងៃហ្នឹង។ សម្រាប់ក្មេងៗជំនាន់ក្រោយ យើងបានរស់នៅជាមួយឪពុកម្ដាយ មានពួកគាត់ជាអ្នកទំនុកបម្រុង ផ្គុងផ្គើម ប៉ុន្តែចាស់ៗជំនាន់មុនដែលរស់នៅក្នុងសង្គ្រាមមិនបានរស់នៅជាមួយឪពុកម្ដាយ ហើយពួកគាត់មិនមានអ្វីដើម្បីជួយទេ។ បើយើងប្រៀបធៀបជីវិតយើងជាមួយពួកគាត់ យើងរស់មានភាពងាយស្រួលជាងពួកគាត់ខ្លាំងមែនទែន។ ពួកគាត់រស់នៅដោយមិនមានសិទ្ធិសេរីភាពអ្វីសោះ។ ពួកគេរស់នៅក្នុងសង្គ្រាម មានការទម្លាក់គ្រាប់បែកនាំគ្នារត់គេចពីគ្រាប់បែក ពាក្យខ្មែរនិយាយថា រស់នៅ ភ្នែកនៅកញ្ចឹងក មានន័យថាពួកគាត់រស់នៅដោយមានភាពភ័យខ្លាច ខ្លាចថាខ្លួននឹងអាចស្លាប់គ្រប់ពេលវេលាបានទាំងអស់ ដោយការទម្លាក់គ្រាប់បែក។

ជាការពិតណាស់ពិភពលោកទាំងមូលបានដឹងពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាថាវាមានភាពសាហាវប៉ុណ្ណា សម្លាប់មនុស្សដោយការបង្អត់អាហារ  សម្លាប់ដោយអាករនឹងធាងត្នោត ឬក៏វាយនឹងគល់។ ពួកគេអាចឃើញថា អ្នកចម្បាំងបានប្រើ ធាងត្នោតមុត ដើម្បីអារបំពង់កដោយវាយនឹងគល់ឫស្សីទម្លាក់ចូលរណ្ដៅឱ្យស្លាប់។ ខ្ញុំបានជួបម្នាក់ដែលគាត់ត្រូវគេវាយសម្លាប់បោះចូលរណ្ដៅ តែមិនទាន់ស្លាប់ ហើយពេលដែលគាត់ដឹងខ្លួនឡើងវិញ គាត់បាននៅក្នុងរណ្ដៅដែលពោរពេញទៅដោយសាកសព ហើយព្យាយាមវារចេញពីរណ្ដៅ ហើយស្រែករកឱ្យគេជួយ។ ពេលដែលដឹងពីរឿងរបស់គាត់ ធ្វើឱ្យខ្ញុំមានការអនិច្ចា និងអាណិតគាត់ខ្លាំងមែនទែន។ បទពិសោធន៍នេះជាអ្វីមួយដែលខ្ញុំចងចាំមិនភ្លេច។ អ្វីដែលសំខាន់ ខ្ញុំអាចយល់ពីទុកលំបាករបស់ពួកគាត់ពេលដែលខ្ញុំបានឮរឿងពីភាពលំបាកនានារបស់ពួកគាត់។ ពេលដែលខ្ញុំ

សម្ភាស ខ្ញុំចូលចិត្តសួរច្រើនអំពីបទពិសោធន៍ពួកគាត់នៅក្នុងសម័យសង្គ្រាមខ្លាំងជាងគេ ដោយសារខ្ញុំមានអារម្មណ៍ថាវាអយុត្តិធម៌ខ្លាំងមែនទែនសម្រាប់ជនជាតិខ្មែរ ដោយសារជាមនុស្ស និង ជាតិសាសន៍ដូចគ្នា ហេតុអីបានត្រូវកាប់សម្លាប់គ្នាបែបនេះ?

អ្វីមួយដែលខ្ញុំចងចាំនោះគឺរឿងអ៊ុំប្រុសទាំងពីររបស់ខ្ញុំ ពេលដែលខ្ញុំបានស្តាប់រឿងរបស់គាត់ ខ្ញុំពិតជាចង់យំ ដោយសារវាមានភាពកម្សត់មែនទែន។ ពួកគាត់ជាបងប្រុសរបស់ឪពុកខ្ញុំ គាត់មានប្រពន្ធដែលកំពុងតែមានផ្ទៃពោះ ហើយម្នាក់ទៀតមានកូនពីរនាក់ហើយ ពួកប៉ុលពត បានយកពួកគាត់ទៅសម្លាប់ចោលទាំងអស់ ទោះប្រពន្ធកំពុងមានផ្ទៃពោះ។ ឪពុកម៉ែខ្ញុំបានប្រាប់ថា ពួកគាត់ជាអ្នកចេះដឹង ហើយប៉ុលពតបានចាប់ពួកគាត់យកទៅដាក់ក្នុងទ្រុងមួយ វាដូចជាគុកអីចឹង ហើយមានម្នាក់ ខ្ញុំមិនថាជាបងប្អូន ឬក៏អីទេ ពេលដែលគាត់ឆ្លងកាត់កន្លែងហ្នឹង គាត់មានសម្លឹងមើលចុងកន្ទុយភ្នែក ហើយបានដឹងថាជាអ៊ុំខ្ញុំដែលនៅក្នុងទ្រុងហ្នឹង។ ពេលខ្ញុំបានស្តាប់នូវរឿងមួយហ្ននឹង ខ្ញុំបានគិតស្រម៉ៃពីរូបភាពហ្នឹង ហើយធ្វើឱ្យខ្ញុំអនិច្ចា និង ខ្លោចចិត្តខ្លាំងបំផុត ធ្វើឱ្យខ្ញុំបានគិតថា តើពួកគាត់មានការលំបាកខ្លាំងប៉ុណ្ណាទៅ ពេលដែលពួកគាត់ជួបរឿងបែបហ្នឹង គេយកទៅដាក់ក្នុងគុកដើម្បីនឹងសម្លាប់ ហើយប្រពន្ធកំពុងតែពរពោះទៀត។ អញ្ចឹងរឿនហ្នឹង ម្នាក់ដែលឃើញបានយករឿងទៅប្រាប់ជីតាខ្ញុំ ហើយក្រុមគ្រួសារខ្ញុំមានអារម្មណ៍ថាទទួលយកអត់បាន។ ម្តាយខ្ញុំគាត់ពិបាកអត់ឃ្លាន ហើយឪពុកខ្ញុំគាត់ស្គមខ្លាំងមែនទែន។ ពេលដែលខ្ញុំទៅស្រុកបាទី ដែលជាស្រុកកំណើតរបស់ឪពុកម្តាយខ្ញុំ ដែលជាកន្លែងខ្ញុំទៅលេងរាល់ឆ្នាំ មួយឆ្នាំទៅពីរបីដង។ ខ្ញុំបានឃើញដើមឈើធំៗពីរ នៅកន្លែងគេបូជាយាយខ្ញុំគាត់ស្លាប់ដោយសារការអត់ឃ្លាន ថែមទាំងគេយកកូនៗគាត់ទៅសម្លាប់ចោលអស់។ ខ្ញុំវាជារឿងមួយដែលគួរឱ្យអណោចអធមខ្លាំង។

សម្រាប់បទពិសោធន៍ដែលខ្ញុំមានតាមរយៈការសម្ភាសមនុស្សដទៃ វាជួយឱ្យខ្ញុំមានសេចក្តីស្រឡាញ់កាន់តែច្រើនចំពោះមនុស្សដទៃ។ ជីវិតរបស់មនុស្សម្នាក់ៗមានតម្លៃខ្លាំងមែនទែន។ ហើយគួបផ្សំដែលខ្ញុំជាអ្នកកាត់សាសនាគ្រីស្ទ ហើយក៏ធ្លាប់ធ្វើជាអ្នកអ្នកផ្សព្វផ្សាយសាសនាផង វាធ្វើឱ្យខ្ញុំរឹតតែស្រឡាញ់អ្នកដទៃថែមទៀត។ ពេលដែលខ្ញុំទៅព្រះវិហារ ខ្ញុំតែងតែថ្លែងសក្ខីភាពពីកិច្ចការពង្សប្រវត្តិ។ ដូនតារបស់យើង ដូចថាគាត់ពិបាកនៅក្នុងសង្គ្រាមហើយ

ហើយ អញ្ជឹងដើម្បីកុំឱ្យជីវិតពួកគាត់ពិបាកថែមទៀត យើងនឹងរៀបចំធ្វើកិច្ចការពង្សប្រវត្តិ ឱ្យពួកគាត់ទៅព្រះវិហារបរិសុទ្ធ ដើម្បីឱ្យគាត់ស្រួលទាំងវិញ ដោយសារមុនគាត់ស្លាប់គឺគាត់ស្លាប់ដោយភាពសាហាវ ដោយការធ្វើទារុណកម្ម អាក្រក់មែនទែន។ អ្វីដែលជួយគាត់បានគឺការធ្វើពិធីបុណ្យជ្រមុជទឹកឱ្យគាត់ ហើយនិងអាចឱ្យគាត់ជ្រះពីអំពើបាប ហើយគាត់អាចទទួលយកដំណឹងល្អទៅថ្ងៃខាងមុខទៀតពេលដែលព្រះយាងមក។ ខ្ញុំមានអំណរគុណចំពោះគម្រោងនេះដែលជួយរក្សាប្រវត្តិសាស្ត្រកម្ពុជា ដែលយើងបានបាត់បង់នៅក្នុងសង្គ្រាម។ ខ្ញុំស្រឡាញ់ថាប្រវត្តិសាស្ត្រនេះត្រូវបានកត់ត្រាដោយសម្លេង ដោយសារតែពីបុរាណ យើងមិនមានជាការថតសម្លេង មានតែជាសិលាចារិក គម្ពីរ ដែលជាភាសាបុរាណពិបាកនឹងយល់។ នៅពេលខ្ញុំស្តាប់ការសម្ភាសទាំងនេះ ខ្ញុំមានបំណងប្រាថ្នាកើនឡើងក្នុងការរៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ប្រទេសខ្ញុំ និងជួយជីដូនជីតារបស់ខ្ញុំ។